# សិលាចារឹកប្រាសាទតាកែវ K.២៧៦

## ១- ព័ត៌មានទូទៅ

ប្រាសាទតាកែវ ជាប្រាសាទមួយស្ថិតនៅក្នុងតំបន់អង្គរ ខេត្តសៀមរាប ដែលចាប់ផ្តើមកសាងឡើងនៅក្នុងរាជ្យព្រះបាទស្រីជ័យវម៌្មទេវទី៥ (ជ័យវរ្ម័នទី៥ គ.ស.៩៦៨-១០០១) និងបន្តរហូតដល់រាជ្យព្រះបាទស្រីសូរ្យវម៌្មទេវទី១ (គ.ស.១០០២-១០៥០)។ ប៉ុន្តែយ៉ាងនេះក្តី ប្រាសាទនេះពុំបានសាងសង់រួចរាល់ទេ។ យើងអាចឃើញក្បាច់ចម្លាក់ល្អមានចំនួនតិចតួចនៅលើផ្ទៃថ្មប្រាសាទ ដែលជាទូទៅជាផ្ទៃទំនេរពុំមានក្បាច់លម្អឡើយ។

នៅប្រាសាទនេះ មានសិលាចារឹកសរុបទាំងអស់ចំនួន៧ផ្ទាំង គឺ K.២៧៥-៧៨ និង K.៥៣៤-៥៣៦។ សិលាចារឹកទាំងនេះធ្លាប់សិក្សាកន្លងមកដោយអ្នកស្រាវជ្រាវជនជាតិភាសាបារាំង។ នៅក្នុងអត្ថបទនេះ យើងជ្រើសរើសយកសិលាចារឹក K.២៧៦ ដែលចារជាភាសាសំស្ក្រឹត១បន្ទាត់ និងខ្មែរបុរាណ២៤បន្ទាត់ មកប្រែសម្រួលជាភាសាខ្មែរទំនើប។ សិលាចារឹកនេះមានទីតាំងនៅលើមេទ្វារត្បូង ប្រកខាងលិច ក្លោងទ្វារចូលខាងក្រៅនៃប្រាសាទតាកែវ។ សិលាចារឹកនេះជាបញ្ជីកត់ត្រាបុណ្យរបស់រាជបុរោហិតព្រះបាទស្រីសូរ្យវម៌្មទី១ គឺព្រាហ្មណ៍ស្រីយោគីស្វរបណ្ឌិតដែលបានថ្វាយតង្វាយទៅកាន់ប្រាសាទនានាដូចជាប្រាសាទកោះកេរ ប្រាសាទនៅអង្វើទន្លេ ប្រាសាទព្រៃបាសាក់ ប្រាសាទស្រីចាម្បេស្វរ ប្រាសាទកន្ទួតទឹក ប្រាសាទបាសែត ប្រាសាទភ្នំបូព៌ ប្រាសាទច្បារបុស្សី ប្រាសាទតាកែវ និងប្រាសាទឯកភ្នំ។ តង្វាយដែលថ្វាយទៅប្រាសាទឯកភ្នំ មានបញ្ជាក់លម្អិតនៅក្នុងសិលាចារឹកនាប្រាសាទឯកភ្នំ K.២១១ ដោយសារលោក គឺជាអ្នកចាត់ចែងការសាងសង់ប្រាសាទនោះ ដើម្បីតម្កល់ព្រះសិវលិង្គឧទ្ទិសថ្វាយចំពោះព្រះបាទស្រីសូរ្យវម៌្មទេវទី១ ដែលមានព្រះនាមថា «ស្រីសូរ្យវម៌្មេស្វរ»[១]។

សិលាចារឹកនេះ ពុំមានចុះកាលបរិច្ឆេទឡើយ ប៉ុន្តែតាមទម្រង់តួអក្សរ គឺចារឡើងក្នុងរវាងស.វ.ទី១១ ក្នុងរាជ្យព្រះបាទស្រីសូរ្យវម៌្មទេវទី១។ ទម្រង់តួអក្សរមានលក្ខណៈល្អ

---

១ សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/14697 ។

វិចិត្រ ច្បាស់ល្អ ចារត្រង់បន្ទាត់ ប៉ុន្តែផ្ទៃថ្មពុំបានរំលីងឱ្យមានផ្ទៃរាបស្មើល្អប៉ុន្មានឡើយ។ បើពិនិត្យលើក្បួនសំណេរវិញ ចំពោះពាក្យខ្មែរ មានប្រើសញ្ញាវិរាមនៅលើតួប្រកប លើកលែងតែពាក្យ «ម្វាយ» «វ្យរ» និង «បី»។ ក្នុងករណីមិនប្រើសញ្ញាវិរាម គេប្រើតម្រួតព្យញ្ជនៈខាងចុងលើខ្លួនឯងដូចពាក្យ «ប្វាន្ន» និង «អំបល្ល» ជាដើម។ ចំណែកក្នុងករណីតួប្រកបខាងចុងពាក្យពុំដាក់សញ្ញាវិរាម ព្យញ្ជនៈខាងដើមពាក្យបន្ទាប់ត្រូវសរសេរនៅខាងក្រោមព្យញ្ជនៈខាងចុងនៃពាក្យទីមួយ។ របៀបដូច្នេះ នាំឱ្យមានការសរសេរតម្រួតពាក្យចាប់ពីពីរបញ្ចូលគ្នា។




ប្លង់សិលាចារឹកនៅក្លោងទ្វារប្រាសាទតាកែវ (ប្រភព៖ កែសម្រួលពី Coedès 1934)

## ២- អត្ថបទដើមជាអក្សរទំនើប

១- ៙៚ឱំនមគ្គិវាទិក្យោគុរុក្យះទេវគ្រីយោគីគ្វរបន្ទិតស្យោទយសិទ្ធិរស្តុ៚

២- ជំនួនិវ្រះកម្រតេងអញ៑គ្រីយោគីគ្វរបន្ទិតស្រុក៑ន្វ៑រកំទ្វាត៑វ៑

៣- បយវ្យាធបុរៈតកម្រតេងជគត្ថ្វិង្គបុរៈមុខវសិម្វាយៈវ្រះត្រិគ្វ

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

៤- លលង្គ៉ោម្វាយិភារតី[២] ស្ទាបនាតិឰគាន◌តកន្ទោងកម្រតេងអញអង្វ៉េ

៥- ទន្ទេតិប្រតិឞ្ឋាវ្រះកម្រតេងអញគ្រីត្រិបុរទហនេគ្វរកនកាង្គស្តចិប

៦- ញ្ជោត្សរអំវលនុភគវតីជ្វនិហេមទោលាម្វាយ◌តកម្រតេង្ផគតិរ

៧- ក្លកិគិរិកាម្វាយតិស្ទាបនាវ្រះកម្រតេងអញគ្រីនាតកេគ្វរទគកុ

៨- ជនុសមស្តាភរណាតគិនុភោគតអំបាល្វនេះហ◌ហេមករង្កម្វាយជ្យង

៩- វ្យរលិង្គប្ប•ខាល្នាសិម្វាយលិង្គប្ប◌រុប្យករង្កម្វាយជ្យង្សិយលិង្គប្ប•

១០- រុប្យប្រតិគ្រហម្វាយជ្យង្គប្បម្វាយ◌រុប្យកលគម្វាយជ្យងប្រម្វាយលិ

១១- ង្គប្ប◌រុទិប្រាកិម្វាយជ្យងប្រម្វាយលិង្គប្ប◌រុប្យភាជនម្វាយជ្យងប្រំបិ

១២- យ◌រុប្យកមន្ទលុម្វាយលិង្គប្ប◌មាយូរច្ឆត្រ•គណាតោយអំបេណគិត

១៣- បំរេ◌តកម្រតេង្ផគតិគ្រិចាម្បេគ្វរតិប្រតិឞ្ឋាវ្រះកម្រតេងអញគ្រី

១៤- ត្រិកុវនញ្ជយអំវល(នុ)ភគវតីគ្រីយកនកាង្គស្តច្បញ្ជោត្សរ•

១៥- ហេមទោលាម្វាយអទ្វំលោម្វាយកនកាង្គ•សិតច្ឆត្រ◌តកម្រតេង្ផគ

១៦- ត្កុំទ្វាតិទិក្តិដៅភូមិកទ្រាវិទ្យាវីរចាំ[៣]ចំនាំគ្វេតតន្ទុលាទិយថាវិភវ

១៧- តកម្រតេង្ផគតិគ្រីជយក្សេត្រសុវណ៌ភាជនម្វាយអង្គុលិយក

១៨- ប្រំវ្យល•វ្រះអគ្រោញសវ៌ទន្ត◌សិតច្ឆត្រសវ៌ទន្ត◌រត្នតប្បសូយ៌្យ

១៩- កាន្តាទិវុទិបទិគះប្វាន្ទ•តម្ប្រម្វាយ◌តកម្រតេងជគតិវុំប្វូវ៌•តិ

២០- ប្រតិឞ្ឋាវ្រះកម្រតេងអញគ្រីត្រិកុវនញ្ជយស្តចបញ្ជោត្សរ◌

២១- តកម្រតេង្ផគតិធ្បាររន្សេ◌វ្រះបីថសវ៌ទន្ត•គន្តិន្សវ៌ទន្តសុវណ៌រ

២២- បិត◌តកម្រតេង្ផគតិហេមគ្រុង្គទុកិប្ទឹត[៤]វ្រះអប្វ៉ាំ◌បញ្ជគូល◌រ

២៣- ណាមទ្វំណាតម្ទាំ◌តកម្រតេង្ផគតិគ្រីនរេន្ទ្រគ្រាមវ្រះស្រុកិភីមបុរមន្តិ

---

[២] លោក សេដែស និងលោក ចេណ្ណឹរ អានជា «តិ» ប៉ុន្តែនៅលើសំណៅផ្តិត យើងឃើញមានចំណុចមួយនៅកណ្តាលរង្វង់ស្រៈ «ិ» ដែលនាំឱ្យយើងអានជា «តី»។

[៣] លោក សេដែស និងលោក ចេណ្ណឹរ អានជា «ចំ»។

[៤] លោក សេដែស និងលោក ចេណ្ណឹរ ពុំអានពាក្យ «ត» នេះទេ។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

២៨- តស្វាបកផ្ទនិរុប្យកលគម្វាយជ្យងិប្រំបីយ៎ះរុប្យករង្គម្វាយជ្យង្សិយ

២៩- ស្រុកិជាគ្រាមវ្រះទក្សិណាតិផ្ទនិរិធិជាចំនាម១ ?

## ៣- អត្ថបទប្រែសម្រួល

(១) ឱម សូមនមស្ការចំពោះព្រះគ្រូមានព្រះឥសូរជាអាទិ៍។ សេចក្តីសម្រេចនិង សេចក្តីចម្រើន ចូរមានដល់ព្រះស្រីយោគីសូរបណ្ឌិត។

(២-៤) តង្វាយ(របស់)ព្រះគម្តែងអញស្រីយោគីសូរបណ្ឌិតស្រុក(នៅ)ផ្ទរកន្ទុត(ព្រៃ នៃ)តំបន់វ្យាធបុរ (ថ្វាយ)ចំពោះគម្តែងជគតលិង្គបុរ(គឺប្រាសាទកោះកេរ មាន) មុខពស់១ ព្រះត្រីសូល(ទម្ងន់)១ភារ ស្ថាបនា(តម្កល់នៅទិស)ឦសាន។

(៤-៦) (តង្វាយ)ចំពោះកន្ទោងគម្តែងអញអង្វើទន្ទេ[៥](មាន) ប្រតិស្ឋានព្រះគម្តែង អញស្រីត្រីបុរទហនេសូរ(ធ្វើអំពី)មាស (ជា)ធំ(នៅក្នុងពិធី)បញ្ចោត្សវ និងព្រះភគវតី[៦] ថ្វាយអង្រឹងមាស១។

(៦-១៣) (តង្វាយ)ចំពោះគម្តែងជគតវកឯក[៧](មាន) គ្រែស្នែង១ ស្ថាបនាព្រះគម្តែង អញស្រីនាដកេសូរព្រះហស្ត១០ ដោយមានបំពាក់គ្រឿងអលង្ការ និង(ថ្វាយនូវ)គោគទ្រព្យ អម្បាលនេះ(មាន) ផ្តិលឬចានមាស១ (ទម្ងន់)២ជញ្ជីង ១០តម្លឹង, ខាលមាស១ (ទម្ងន់)១០ តម្លឹង, ផ្តិលឬចានប្រាក់១ (ទម្ងន់)៣ជញ្ជីង ១០តម្លឹង, កន្ទោរស្តោះប្រាក់១ (ទម្ងន់)១១ ជញ្ជីង, ថូក្លស់ប្រាក់១ ៦(ទម្ងន់)ជញ្ជីង ១០តម្លឹង, ថូរុទិប្រាក់១ (ទម្ងន់)៦ជញ្ជីង ១០តម្លឹង, ភាជន៍ប្រាក់១ (ទម្ងន់)៨ជញ្ជីង, ថូកមណ្ឌលុ១ (ទម្ងន់)១០តម្លឹង, មយូរឆ័ត្រ, (និង)ក្រុមអ្នក បែន(ស្រូវ)ជាអ្នកបម្រើ(ការ)។

---

[៥] «កន្ទោងគម្តែងអញអង្វើទន្ទេ» ឃើញមាននៅក្នុងសិលាចារឹកលង្វែក K.១៣៦ សិលាចារឹកប្រាសាទត្នោត ជុំ K.១៤៣ សិលាចារឹកប្រាសាទចារ K.២៥៧ សិលាចារឹកប្រាសាទតាកែវ K.២៧៧ សិលាចារឹកប្រាសាទអ្នក បួស/នាគបួស K.៣៤២។ ចំណែកឯសិលាចារឹកបង្ហាញពីបូងដីនៅប្រាសាទឃ្មាំងខាងជើង K.៩៤២ ក៏មាន បង្ហាញពីទីតាំងអង្វើទន្ទេផងដែរ។

[៦] ព្រះភគវតី គឺទេពស្រីជាមហេសីរបស់ទេពប្រុសណាមួយ។

[៧] សូមអានបន្ថែម៖ https://ams.com.kh/khmercivilization/detail/14901។

អត្ថបទដោយ៖ ហ៊ុន ឈុនតេង

(១៣-១៥) (តង្វាយ)ចំពោះកម្តែងជគតស្រីចាម្បេស្វរ(មាន) ប្រតិស្ឋានព្រះកម្តែងអញស្រីត្រីភុវនញ្ជ័យនិងព្រះភគវតីស្រី(ធ្វើអំពី)មាស ជាធំ(នៅក្នុងពិធី)បញ្ចោត្សវ អង្រឹងមាស១ អទ្ធំលោមាស១ (និង)ស្វេតឆត្រ។

(១៥-១៩) (តង្វាយ)ចំពោះកម្តែងជគតកន្ទួតទឹក (គឺ)ជាវក្ខមិកទ្វារទ្យារីរ(ថ្វាយ) (និង)រៀបចំគ្រឿងវណ្ដាប់បូជាមានអង្ករសម្រិតជាដើម តាមទ្រព្យដែលមាន។

(១៩-២០) (តង្វាយ)ចំពោះកម្តែងជគតស្រីជ័យក្សេត្រ(គឺប្រាសាទបាសែត (មាន) ភាជន៍មាស១, ចិញ្ចៀន៧, ព្រះអទ្រោញក្នុកសុទ្ធ, ស្វេតឆត្រក្នុកសុទ្ធ, រតនមណី១០ (មាន) កែវស្សូរ្យកាន្តជាដើម, ចូវុទិ, កន្ទោរស្ពោះ៤ (និង)ដំរី១។

(១៩-២០) (តង្វាយ)ចំពោះកម្តែងជគតភ្នំបូព៌ (គឺ)ប្រតិស្ឋានព្រះកម្តែងអញស្រីត្រីភុវនញ្ជ័យជាធំ(ក្នុងពិធី)បញ្ចោត្សវ។

(២១-២២) (តង្វាយ)ចំពោះកម្តែងជគតច្បារឫស្សី(មាន) គ្រែព្រះ(ធម៌ធ្វើពី)ក្នុកសុទ្ធ (និង)គន្ទិន(ធ្វើពី)ក្នុកសុទ្ធរំលេចមាស។

(២២-២៣) (តង្វាយ)ចំពោះកម្តែងជគតហេមស្រឹង្គ(គឺប្រាសាទតាកែវ) ថ្វាយគ្រឿងអលង្ការដល់ព្រះបដិមា, បញ្ចសូល៍ (និង)ដំបងចម្បាំងសម្រាប់អ្នករបាំ។

(២៣-២៥) (តង្វាយ)ចំពោះកម្តែងជគតស្រីនរេន្ទ្រគ្រាម(គឺប្រាសាទឯកភ្នំ) (នៅ) ព្រះស្រុកភីមបុរៈ ដែលលោក(គឺព្រាហ្មណ៍យោគីស្វរបណ្ឌិត)ជាអ្នកស្ថាបនា(មាន) ថ្វាយថូក្លស់ប្រាក់១ (ទម្ងន់)៨ជញ្ជីង, (និង)ផ្តិលឬចានប្រាក់១ (ទម្ងន់)៣ជញ្ជីង។ ស្រុកជាគ្រាម(ជា)ព្រះតង្វាយដឹងគុណ ថ្វាយ(ដល់ប្រាសាទនេះ)ជាគ្រឿងចំណាំបូជា។

## ៤- វាក្យសព្ទ

| | |
|---|---|
| **ករង្គ** | (សំ.) ថូ ពែង ផ្តិល ឬចាន។ |
| **កលគ** | (សំ.) ថូក្លស់ ថូឬភាជន៍សម្រាប់ស្រង់ទឹក។ |
| **គន្ទិន** | វត្ថុប្រើប្រាស់ម្យ៉ាងដែលគេពុំទាន់អាចកំណត់ន័យបាន។ |
| **ជំនូនិ** | ជំនូន តង្វាយ។ **ជំនូនិ** < **ជូនិ** "ជូន"។ |
| **ចំនាំ** | គ្រឿងវណ្ដាប់បូជា គ្រឿងរៀបចំសម្រាប់បូជា។ |

អត្ថបទដោយៈ ហ៊ុន ឈុនតេង

| | |
|---|---|
| ត | ដ៏, ដល់, ចំពោះ,...។ |
| តម្រូ | ដំរី។ |
| ថ្មី | គ្រឿងអលង្ការ គ្រឿងប្រដាប់កាយ។ |
| ទក្សិណា | (សំ.) រង្វាន់ឬប្រាក់សគុណចំពោះគ្រូ ឬព្រាហ្មណ៍, តង្វាយ,...។ |
| បីថ | (សំ.) កៅអី អាសនៈ បល្ល័ង្ក គ្រែព្រះធម៌(?)។ |
| ប្រតិគ្រហ | (សំ.) កន្ទោរស្តោះ។ ដូចពាក្យ **បទិគះ** ដែរ។ |
| ភារ | (សំ.) ជាខ្នាតរង្វាស់ទម្ងន់របស់ឥណ្ឌា។ |
| រណោមទ្ទំណ | (សំ. រណ = ចម្បាំង សង្គ្រាម + មទ៌ន = កិន កម្ទេច បុក...) ដំបងចម្បាំង ដំបង។ |
| ម្ទាំ | អ្នកពាំ។ |
| រូប្យ | (សំ.) ដែលធ្វើពីប្រាក់ ដែលមានរូបល្អ។ |
| លង្គៅ | ស្ពាន់។ |
| វុទិ | (សំ.) ថូម្យ៉ាង។ |
| ត្វេតតន្ទុល | (សំ. < ត្វេត = ស + តន្ទុល =អង្ករ) អង្ករសម្រិត។ |
| សវ្វ៌ទន្ត | (សំ. សវ្វ៌ = សព្វ + ទន្ត = ធ្មេញ ភ្លុក) ភ្លុកសុទ្ធ។ |
| ស្នាបក | (សំ.) អ្នកស្ពាបនា។ |
| ហេមទោលា | (សំ. ហេម = មាស + ទោលា = អង្រឹង) អង្រឹងមាស។ |
| អង្គុលិយក | (សំ.) ចិញ្ចៀន។ |
| អច៌ា | (សំ. អចា៌) រូបបដិមា។ |
| អទ្ធំលោ | វត្ថុប្រើប្រាស់ម្យ៉ាងដែលគេពុំទាន់អាចកំណត់ន័យបាន។ |
| អំបេណ | (< បេនិ =បែន) អ្នកបែន(ស្រូវ)។ |

# ឯកសារពិគ្រោះ

Coedès Georges.

1934. III. Epigraphie. In: *Bulletin de l'Ecole française d'Extrême-Orient*. Tome 34, pp. 417-427; doi : https://doi.org/10.3406/befeo.1934.4971

Cœdès, G.

1952. Inscriptions de Pràsàt Tà Kèv in *Inscriptions du Cambodge*, Vol. 4. Paris.

Jenner, P.

Piédroit of Pràsàt Tà Kèv in Part xml, № 57. http://sealang.net/ok/corpus.htm

# បញ្ជីរូបភាព



រូបថតប្រាសាទតាកែវ

(ប្រភពរូប៖ https://commons.wikimedia.org/wiki/File:Temple_Facade-Angkor.jpg)

អត្ថបទដោយ៖ ហ៊ុន ឈុនតេង



សំណៅផ្តិតសិលាចារឹកប្រាសាទតាកែវ K.២៧៦ (ប្រភពរូបៈ EFEO_ CAM17034)

អត្ថបទដោយៈ ហ៊ិន ឈុនតេង